**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

**សភាព្រហ្មទណ្ឌ**
**សំណុំរឿងព្រហ្មទណ្ឌ**
លេខ ១៧៥
ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩

**សាលដីកា**
លេខ ៦២ IV
ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០

# សាលដីកា
## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចខាងក្រោម៖

១.ឯកឧត្តម [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
២.លោក [redacted] ជាចៅក្រម
៣.លោក [redacted] ជាចៅក្រម
៤.លោក [redacted] ជាចៅក្រម
៥.លោក [redacted] ជាចៅក្រម

**ចៅក្រមរបាយការណ៍**

-លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

-កញ្ញា [redacted]

**តំណាងមហាអយ្យការ**

-លោក [redacted] ជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ១៧៣ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] វាសនា ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៦២ ក្រVសស ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន៖

១.ជនជាប់ចោទឈ្មោះ [redacted] **វាសនា** ហៅ **ឈាន់** ភេទប្រុស អាយុ ១៦ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅរស់ ទោសពីមុនគ្មានៗ (អ្នកប្តឹងសាទុក្ខ)

មេធាវីការពារសិទ្ធិលោក [redacted] **ទិមុល**



Scanned with CamScanner

**ជាប់ចោទពីបទ** សមគំនិតក្នុងអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើប្រាស់អាវុធ ប្រព្រឹត្តនៅចំណុចភូមិសាក់យ ឃុំបុសខ្នុរ ស្រុកចម្ការលើ ខេត្តកំពង់ចាម កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ២១៨ កថាខណ្ឌទី១ ចំណុចទី២ នៃក្រមព្រហ្មទណ្ឌ។

២.ជនជាប់ចោទឈ្មោះ [redacted] សុខជីន ហៅ [redacted] ជីន ភេទប្រុស អាយុ ១៧ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវទោសពីមុនគ្មាន។ (គេចខ្លួន)

**ជាប់ចោទពីបទ** ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើប្រាស់អាវុធ ប្រព្រឹត្តនៅចំណុចភូមិសាក់យ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ កថាខណ្ឌទី១ ចំណុចទី២ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] តារុណ ភេទប្រុស អាយុ២៤ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកំពង់ចាម។

ជនរងគ្រោះឈ្មោះ [redacted] តារា ភេទប្រុស អាយុ១៩ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តកំពង់ចាម។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង ១៩ និង ៥០ នាទី នៅចំណុចផ្លូវជាតិលេខ ៧១ ស្ថិតនៅភូមិសាក់យ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម មានករណីហិង្សាដោយចេតនាមួយដែលបង្កឡើងដោយឈ្មោះ [redacted] វាសនា អាយុ១៦ឆ្នាំ និងឈ្មោះ [redacted] សុខជីន ហៅ [redacted] ជីន អាយុ ១៧ ឆ្នាំ ដោយអ្នកទាំងពីរបានធ្វើសកម្មភាពជិះម៉ូតូយកកាំបិតកាប់លើឈ្មោះ [redacted] តារា បណ្តាលឱ្យរងរបួសចំស្មាខាងឆ្វេងជាទម្ងន់ ហើយជនជាប់ចោទទាំងពីរនាក់រត់គេចខ្លួនពីកន្លែងកើតហេតុ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ១៦០ (ធ) ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ចាម ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១.ផ្តន្ទាទោសឈ្មោះ [redacted] វាសនា ភេទប្រុស អាយុ ១៦ឆ្នាំ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ២ (ពីរ) ឆ្នាំ គិតពីថ្ងៃឃាត់ខ្លួន ពីបទ សមគំនិតក្នុងអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើប្រាស់អាវុធ ប្រព្រឹត្តនៅភូមិសាក់យ



Scanned with CamScanner

ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ២១៨ កថាខណ្ឌទី ១ ចំណុចទី ២ នៃក្រមព្រហ្មទណ្ឌ។

២.ផ្តន្ទាទោសឈ្មោះ [redacted] សុខជីន ភេទប្រុស អាយុ ១៧ ឆ្នាំ (មានសារវ័តាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ២ (ពីរ) ឆ្នាំ គិតពីថ្ងៃឃាត់ខ្លួន ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើប្រាស់អាវុធ ប្រព្រឹត្តនៅភូមិសាក់ាយ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ កថាខណ្ឌទី ១ ចំណុចទី ២ នៃក្រមព្រហ្មទណ្ឌ។

៣.ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] សុខជីន ហៅ [redacted] ជីន ភេទប្រុស (មានសារវ័តាជាតិដូចខាងលើ) មកផ្តន្ទាទោសតាមអំណាចសាលក្រមនេះ តាមបញ្ញត្តិមាត្រា ៣៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

៤.បង្គាប់ឱ្យជនជាប់ចោទខាងលើរួមគ្នាសងសំណងរដ្ឋប្បវេណីចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល ឱ្យទៅឈ្មោះ [redacted] តាក់ ភេទប្រុស អាយុ ២០ឆ្នាំ។

សាលក្រមនេះជំនុំជម្រះ នៅថ្ងៃច័ន្ទ ០៩កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៤ ខែមករា គ.ស. ២០១៩ និងប្រកាសជាសាធារណៈ នៅថ្ងៃព្រហស្បតិ៍ ០២រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ គ.ស. ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វាសនា កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សុខជីន បើកសិទ្ធិប្តឹងទាស់ ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១១ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] វាសនា ហៅ ឈាន់ ប្តឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៦០ (ឆ) ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ចាម ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៦២ ក្រVសស ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ១១ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩ របស់ជនជាប់ចោទ [redacted] វាសនា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ខ្ទះ។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៦០ "ឆ" ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ចាមទុកជាបានការ លើកលែងតែការផ្តន្ទាទោស និងបង្គាប់ឱ្យជនជាប់ចោទ [redacted] វាសនា សងសំណងរដ្ឋប្បវេណីត្រូវបដិសេធចោល។



Scanned with CamScanner

៣.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] វាសនា ដាក់ពន្ធនាគារកំណត់ ០២ (ពីរ) ឆ្នាំ ពីបទសមគំនិតក្នុងអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើប្រាស់អាវុធ ប្រព្រឹត្ត នៅចំណុចភូមិសារ៉ាយ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ២១៨ កថាខណ្ឌទី ១ ចំណុចទី ២ នៃក្រមព្រហ្មទណ្ឌ។

៤.បង្គាប់ឱ្យឈ្មោះ [redacted] រឿន និងឈ្មោះ [redacted] ចាន់នី ជាអាណាព្យាបាលរបស់ឈ្មោះ [redacted] វាសនា រួមគ្នាសងសំណងថ្លៃព្យាបាលជំងឺចិត្តចំនួន ៤.០០០.០០០៛ (បួនលានរៀល) ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] តាក។ ទាមទារលើសពីនេះត្រូវបដិសេធចោល។

៥.បន្តការឃុំខ្លួនជនជាប់ចោទតាមនីតិវិធីច្បាប់។

សាលដីកានេះជំនុំជម្រះ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈ នៅសាលសវនាការនៃសាលាឧទ្ធរណ៍ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វាសនា កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ ១៧៣ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] វាសនា ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៦២ ក្រVសស ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

**នាពេលសវនាការ**

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលសន្និដ្ឋានថា នៅក្នុងសារណាចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ របស់ជនជាប់ចោទ [redacted] វាសនា បានបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខរបស់ខ្លួនថា៖ នៅពេលកើតហេតុ ខ្លួនបានបើកម៉ូតូឌុបឈ្មោះ [redacted] សុខជីន ពិតមែន ប៉ុន្តែខ្លួនពុំបានឃើញដាវរបស់ [redacted] ជីន ទេ ហើយក៏ពុំបានដឹងថា [redacted] ជីន កាប់ទៅលើជនរងគ្រោះនោះដែរ។ ការសម្រេចផ្តន្ទាទោសខ្លួនដាក់ពន្ធនាគារ ០២ ឆ្នាំ ពុំមានភាពយុត្តិធម៌ចំពោះខ្លួន ពីព្រោះខ្លួនពុំបានប្រព្រឹត្ត។ ការដោះសាររបស់ជនជាប់ចោទ [redacted] វាសនា នៅក្នុងសារណាថា ខ្លួនពុំបានដឹងថា គូកនរបស់ខ្លួនមានដាវ និងពុំបានឃើញគូកនរបស់ខ្លួនកាប់ទៅ



Scanned with CamScanner

លើជនរងគ្រោះ ពុំសមហេតុផលគួរឱ្យជឿបានទេ ដោយហេតុថា ដាវពុំមែនជាវត្ថុតូចដែលអាចលាក់នាំឱ្យមើលពុំឃើញ នោះឡើយ។ ម្យ៉ាងវិញទៀត ជនដៃដល់ (សុខជីន) អាចកាប់ទៅលើជនរងគ្រោះបាន លុះត្រាតែអ្នកបើកម៉ូតូ អែបជិតជនរងគ្រោះទើបជនដៃដល់អាចកាប់បាន។ សកម្មភាពរបស់ឈ្មោះ [redacted] វាសនា មានភាពស៊ីសង្វាក់ទៅនឹងចម្លើយ នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌។ អំពើរបស់ជនជាប់ចោទ គឺជាបទ សមគំនិតក្នុងបទហិង្សា ដោយចេតនាមានស្ថានទម្ងន់ទោស ដោយប្រើអាវុធ បទល្មើសដែលបានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ២៩ មាត្រា ២១៨ កថាខណ្ឌទី ១ ចំណុចទី ២ នៃក្រមព្រហ្មទណ្ឌ។ សាលដីការបស់សាលាឧទ្ធរណ៍ដែលបានសម្រេចមកនេះ មានកស្តុតាង និងសំអាងហេតុត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការ។

ហេតុដូច្នេះ តំណាងមហាអយ្យការប្តឹងសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចៈ

តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៦២ ក្រ.វសស ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍។

-ក្រឡាបញ្ជីអានសារណាការពាររបស់ជនជាប់ចោទឈ្មោះ [redacted] វាសនា ។

-ជនរងគ្រោះឈ្មោះ [redacted] តារា បានឆ្លើយថា ខ្លួនជាជនរងគ្រោះនៅក្នុងរឿងនេះ ហើយខ្លួនបានខូចដៃមួយចំហៀង ដោយសារតែការកាប់របស់ជនជាប់ចោទ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ការុណា បានឆ្លើយថា ខ្លួនឧបប្អូនរបស់ខ្លួនដែលជាជនរងគ្រោះជិះម៉ូតូធម្មតា ដោយជិះបណ្តោយផ្លូវគ្នាជាមួយនឹងជនជាប់ចោទ។ ខ្លួនជិះយឺតៗ ហើយមិនដឹងខ្លួននោះទេថា ជនជាប់ចោទជិះពីក្រោយ ស្រាប់តែជនជាប់ចោទកាប់មកលើប្អូនខ្លួនដែលជាជនរងគ្រោះតែម្តង បន្ទាប់ពីកាប់ជនរងគ្រោះរួចហើយ អ្នកទាំងពីរនេះបានឈប់ម៉ូតូនៅពីមុខខ្លួនថែមទៀត ហើយពេលពួកខ្លួនស្រែកឱ្យគេជួយ ទើបជនជាប់ចោទទាំងពីរជិះចេញទៅ ហើយខ្លួនក៏ឧបប្អូនរបស់ខ្លួនទៅកាន់មន្ទីរពេទ្យតែម្តង។ ខ្លួនសំណូមពរ សុំឱ្យតុលាការសម្រេចឱ្យជនជាប់ជាប់សងសំណងចំនួន ១២ ០០០ ០០០ (ដប់ពីរលាន) រៀល។

-លោក [redacted] វិបុល មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វាសនា បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីរបស់ខ្លួនមិនបានចូលរួមសមគំនិតក្នុងការប្រព្រឹត្តបទល្មើសនេះទេ គ្រាន់តែជួយយកអាសារមិត្តតែប៉ុណ្ណោះ ហើយពុំមានសាក្សីបញ្ជាក់នោះដែរ ដូច្នេះ នៅមានវិមតិសង្ស័យនៅឡើយ ហេតុដូចនេះ ខ្លួនសំណូមពរ សុំឱ្យតុលាការកំពូលមេត្តាសម្រេចដោះលែងកូនក្តីខ្លួនឱ្យមានសេរីភាព។



Scanned with CamScanner

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណាបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

១.យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៧៣ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩ របស់ជនជាប់ចោទ [redacted] វាសនា ហៅ ឈាន់ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៤១៧ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.យល់ឃើញថា តាមសារណាបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ជនជាប់ចោទ [redacted] វាសនា ក៏ដូចជាការលើកឡើងរបស់មេធាវីការពារសិទ្ធិជនជាប់ចោទនាពេលសវនាការនេះដែរ បានសុំឱ្យតុលាការកំពូលសម្រេចឱ្យជនជាប់ចោទ [redacted] វាសនា រួចខ្លួនពីបទចោទ ដោយបានលើកឡើងនូវមូលហេតុថា ជនជាប់ចោទពុំបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ទេ តាមពិតការឱបឈ្មោះ [redacted]ជីន ទៅផ្ទះរបស់ឈ្មោះនេះ មិនបានដឹងថា [redacted]ជីន បានលាក់ដាវទុកនៅត្រង់ណានោះទេ និងមិនដឹងអំពីបំណងរបស់ [redacted]ជីន ដែរ នោះ តុលាការកំពូលពិនិត្យលើចម្លើយរបស់ជនជាប់ចោទ [redacted] វាសនា ផ្ទាល់ នៅដំណាក់កាលស៊ើបសួរថា ខ្លួនបានដឹងនិងឃើញឈ្មោះ [redacted]ជីន លាក់ដាវនៅជើងខោ ហើយពេលដើរមកដល់ម៉ូតូបានយកដាវនោះដាក់លើកែបម៉ូតូ និងថា មុននឹងឈ្មោះ [redacted]ជីន កាន់ជនរងគ្រោះ [redacted]ជីន បានសួរថា អ្នកស្វាយទាបឬទេ ខ្លួនក៏ប្រាប់ថា ជនរងគ្រោះជាអ្នកស្វាយទាប ហើយឈ្មោះ [redacted]ជីន បានកាប់ជនរងគ្រោះ រួចខ្លួនក៏ជិះគេចខ្លួន ដែលជាចម្លើយមានភាពស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនរងគ្រោះ និង ដើមបណ្តឹងរដ្ឋប្បវេណី ដែលជាបងប្រុសរបស់ជនរងគ្រោះដែលជិះម៉ូតូជាមួយគ្នាថា បន្ទាប់ពីកាប់ជនរងគ្រោះរួចហើយ អ្នកទាំងពីរនេះបានឈប់ម៉ូតូនៅពីមុខខ្លួនថែមទៀត ហើយពេលពួកខ្លួនស្រែកឱ្យគេជួយ ទើបជនជាប់ចោទទាំងពីរជិះចេញទៅ តុលាការកំពូលអាចកំណត់បានថា ជនជាប់ចោទ [redacted] វាសនា មានចេតនាពិតប្រាកដក្នុងការរួបរួមគ្នាជាមួយជនជាប់ចោទ [redacted]ជីន កាន់ទៅលើជនរងគ្រោះ បណ្តាលឱ្យរងរបួស



Scanned with CamScanner

ធ្ងន់ធ្ងរ។ លើសពីនេះ ការអះអាងរបស់ជនជាប់ចោទដែលថា មិនបានសមគំនិតជាមួយជនជាប់ចោទ [redacted] សុខជីន នោះ ជនជាប់ចោទគ្មានភស្តុតាងមកបញ្ជាក់ទេ ប៉ុន្តែ តាមអង្គហេតុនេះ តុលាការកំពូលពិនិត្យឃើញថា បន្ទាប់ពីជនជាប់ចោទ [redacted] ជីន កាន់ទៅលើជនរងគ្រោះហើយ ជនជាប់ចោទ [redacted] វាសនា ដែលជាអ្នកឌុបមិនបានទៅរាយការណ៍ ឬនាំជនជាប់ចោទ [redacted] ជីន ទៅប្រគល់ជូនសមត្ថកិច្ច ដើម្បីបញ្ជាក់បង្ហាញថា ខ្លួនមិនមានចេតនាចូលរួមប្រព្រឹត្តបទល្មើសទេ តែផ្ទុយទៅវិញ ជនជាប់ចោទបានជិះម៉ូតូដឹកគ្នារត់គេចខ្លួនបាត់ ដែលអាចឱ្យតុលាការកំពូលកំណត់បានថា ជនជាប់ចោទ [redacted] វាសនា មានចេតនាទុច្ចរិតក្នុងការប្រព្រឹត្តអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស បទល្មើសព្រហ្មទណ្ឌមានចែងនិង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ និងមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ហើយ ប៉ុន្តែមិនមែនជាអំពើសមគំនិតឡើយ។ ចំណែក ការប្រកាសទោស ០២ ឆ្នាំ លើជនជាប់ចោទ [redacted] វាសនា ដែលជាអនីតិជន មានលក្ខណៈត្រឹមត្រូវតាមបញ្ញត្តិមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌដែលកំណត់អំពីអតិបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ឃើញថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទ មានមូលហេតុមិនត្រូវតាមការកំណត់ត្រង់ចំណុចណាមួយនៃមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ។

៣.យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៦២ ក្រ.សស ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមច្បាប់ លើកលែងតែឈ្មោះបទល្មើស គប្បីកែប្រែដោយមិនបង្អិល។

**ហេតុដូច្នេះ**

**សម្រេច**

១.**បដិសេធ** បណ្តឹងសាទុក្ខលេខ ១៧៣ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩ របស់ជនជាប់ចោទ [redacted] វាសនា ហៅ ឈាន់។

២.**តម្កល់** សាលដីកាព្រហ្មទណ្ឌលេខ ៦២ ក្រ.សស ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការ ដោយគ្រាន់តែកែប្រែឈ្មោះបទល្មើសពីបទសមគំនិត ទៅជាបទ "ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស បទល្មើសព្រហ្មទណ្ឌមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ និងមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ" វិញ ។

Scanned with CamScanner

សាលដីកានេះ បានជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ និង ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០។

Scanned with CamScanner